ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

គណៈកម្មាធិការលទ្ធកម្ម

លេខ :..១៧០....បទ.គល

ថ្ងៃ ៣ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង

## ស្ដីពីការអញ្ជើញចូលរួមដេញថ្លៃបំពាក់ឧបករណ៍បច្ចេកទេស និងដំឡើងកម្មវិធីគ្រប់គ្រងមន្ត្រីរាជការនៃក្រសួងសុខាភិបាលតាមបច្ចេកវិទ្យាព័ត៌មានវិទ្យានៅជាន់ក្រោមដីនៃអគារមិត្តភាពទីស្ដីការគណៈរដ្ឋមន្ត្រី, ជួសជុលថែទាំសម្ភារៈបច្ចេកទេសកម្រងកម្មវិធីកុំព្យូទ័រនៅជាន់ក្រោមដីនៃអគារមិត្តភាព ទីស្ដីការគណៈរដ្ឋមន្ត្រី, ជួសជុលនិងរៀបចំបំពាក់ប្រព័ន្ធសម្រាប់ធ្វើលំហាត់សមយុទ្ធវាយប្រហារ និងការថែទាំប្រព័ន្ធការពារនិងឆ្លើយតបបញ្ហាបន្ទាន់ផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងជួសជុល ថែទាំ ដាក់ដំណើរការ និងពង្រីកប្រព័ន្ធគេហទំព័រនិងសារអេឡិកត្រូនិករបស់រាជរដ្ឋាភិបាលនៅអគារមិត្តភាព ទីស្ដីការគណៈរដ្ឋមន្ត្រី

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សូមជូនដំណឹងចំពោះក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកតបុគ្គល)ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា ៖ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការបំពាក់ឧបករណ៍បច្ចេកទេស និងដំឡើងកម្មវិធីគ្រប់គ្រងមន្ត្រីរាជការនៃក្រសួងសុខាភិបាល, ជួសជុលថែទាំសម្ភារៈបច្ចេកទេសកម្រងកម្មវិធីកុំព្យូទ័រ, ជួសជុល និងរៀបចំបំពាក់ប្រព័ន្ធសម្រាប់ធ្វើលំហាត់សមយុទ្ធវាយប្រហារ និងការថែទាំប្រព័ន្ធការពារ និងឆ្លើយតបបញ្ហាបន្ទាន់ផ្នែកសន្តិសុខ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ព្រមទាំងជួសជុល ថែទាំ ដាក់ដំណើរការ និងពង្រីកប្រព័ន្ធគេហទំព័រនិងសារអេឡិកត្រូនិករបស់រាជរដ្ឋាភិបាល។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំសំណើដេញថ្លៃសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលមានអាសយដ្ឋានអគារលេខ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ចាប់ពី ថ្ងៃទី.៣១. ខែឧសភា.ឆ្នាំ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ( ទូរសព្ទទាក់ទងលេខ ០២៣ ៤២៧ ៥០៧)។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅវេលាម៉ោង..១៦:៣០...រសៀល ថ្ងៃទី.៧.....ខែកក្កដា.ឆ្នាំ២០១៩។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង.១៦:០០រសៀល ថ្ងៃទី..៧..... ខែកក្កដា. ឆ្នាំ២០១៩។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់ឯកសារដេញថ្លៃ បានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានបន្ថែមដែលទាក់ទងនឹងការដេញថ្លៃនេះ។

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

អនុប្រធានទី១

សារ៉ាក់ ខាន់

ចម្លងជូន :

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ឯកសារ កាលប្បវត្តិ

បានពិនិត្យត្រឹមត្រូវ

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ